**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**
**PHNOM PENH SEZ PLC.**
ទីស្នាក់ការក្រុមហ៊ុនៈ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ
ផ្លូវជាតិលេខ៤ ភូមិកំរៀង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ
អត្តលេខចុះបញ្ជីៈ 00006448

លេខៈ០៣៦/២២-PPSEZ

# សេចក្តីប្រកាស
# អំពី
# ការបញ្ចប់ដំណើរការមជ្ឈត្តការ ដោយភាគីវិវាទ COLBEN និង CEZH (COLBEN) ប្រឆាំងនឹងក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី** មានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនថា មជ្ឈត្តកម្មដែលដាក់ពាក្យបណ្តឹងដោយ Colben ប្រឆាំងនឹង PPSP ឥឡូវនេះត្រូវបានបញ្ចប់។ មជ្ឈមណ្ឌលអន្តរជាតិនៃមជ្ឈត្តការសិង្ហបុរី (Singapore International Arbitration Centre )នៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២២ បានធ្វើមជ្ឈវិនិច្ឆ័យស្ថាពរដូចខាងក្រោមៈ

១. (ក) Colben ត្រូវបង់ទឹកប្រាក់សរុបចំនួន SGD ៤៧២.៥០០ និង USD ១១២.៥៧៦,៥៧ ទៅឱ្យ PPSP ទាក់ទងនឹងការចំណាយដោយ PPSP ជាលទ្ធផលនៃការដកពាក្យបណ្តឹងរបស់ Colben នៅមជ្ឈត្តកម្ម។

(ខ) ការទាមទារសំណងរបស់ PPSP ត្រូវបានច្រានចោល។

(គ) PPSP គឺត្រូវបង់ថ្លៃចំណាយ Colben ដែលកើតឡើងក្នុងការការពារការទាមទារសំណងសរុប SGD ១០៤.៥១០,៤៧ និង

(ឃ) ថ្លៃសេវា និងការចំណាយរបស់ស្ថាប័នមជ្ឈត្តកម្ម និងសាលាក្តីដែលកើតឡើងក្នុងមជ្ឈត្តកម្មគឺត្រូវចែករំលែករវាងភាគីវិវាទនៃមជ្ឈត្តកម្មក្នុងសមាមាត្រ ៧៥% ពោលគឺ SGD ៨៧.៨៥៣,៧៥ ដោយ Colben និង ២៥% ពោលគឺ SGD ២៩.២៨៤,៥៨ ដោយ PPSP ។

២.មជ្ឈវិនិច្ឆ័យស្ថាពរគឺស្ថិតនៅក្នុងការដោះស្រាយពេញលេញនៃការទាមទារទាំងអស់ទាក់ទងនឹងការទាមទារសំណងដោយ PPSP និងអាជ្ញាកណ្តាលផងដែរ។

៣. យោងតាមមជ្ឈវិនិច្ឆ័យស្ថាពរ ប្រសិនបើការទូទាត់ដែលបានផ្តល់ក្នុង (ក), (គ) និង (ឃ) ខាងលើមិនត្រូវបានធ្វើឡើងមុន ៣០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃមជ្ឈវិនិច្ឆ័យស្ថាពរ ការប្រាក់សាមញ្ញក្រោយមជ្ឈវិនិច្ឆ័យស្ថាពរក្នុងអត្រា ៥,៣៣% ក្នុងមួយឆ្នាំនឹងត្រូវបានទទួលដោយចាប់ផ្តើម៣០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃមជ្ឈវិនិច្ឆ័យស្ថាពររហូតដល់ពេលដែលការទូទាត់ត្រូវបានធ្វើឡើង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបដោយក្តីអនុគ្រោះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២២
**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី
PHNOM PENH SEZ PLC.
KINGDOM OF CAMBODIA